# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ១៣២ ក្រ៩ "ន"

ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៥៩៤

ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ៧៩០

ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ៤១៤៨

ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង៨ព្រឹក នៅសាលសវនាការទី៤ ដោយមានសមាសភាពជំនុំជម្រះ ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក ចៅក្រមប្រឹក្សាជំនុំជម្រះ

-លោក ចៅក្រមប្រឹក្សាជំនុំជម្រះ

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៩៤ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted] កុសល ហៅ ស្គាស់ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើត [redacted] ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវបេតុង ភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ធា "រស់" ម្តាយឈ្មោះ [redacted] ធារ៉ា "ស្លាប់" ប្រពន្ធឈ្មោះ ពេជ្រ គ្មានកូន ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន ធ្លាប់ជាប់ពន្ធនាគាររយៈពេល២ឆ្នាំពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ (ក្នុងឃុំ)

ឃុំខ្លួននៅម១ តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៤២៨ "គ១"ដឃង/១៤.៩.២០២១

**-ដោយចាត់តាំងលោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។**

ជាប់ចោទពីបទ ៖ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ ៣៣១ ផ្លូវលេខ៣៥៥ ក្រុម១ ភូមិទួលគោក សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

## **អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង១៥និង៥០នាទី ជនរងគ្រោះជនជាតិចិនដើរនៅចំណុចមុខផ្ទះលេខ៣៣១ ផ្លូវ៣៥៥ ក្រុម១ ភូមិទួលគោក សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ស្រាប់តែជនសង្ស័យឈ្មោះ [redacted] កុសល ហៅ ស្អាស់ ភេទប្រុស អាយុ២៨ឆ្នាំ បើកម៉ូតូចូលទៅជិតជនរងគ្រោះរួចធ្វើសកម្មភាពឆក់យកកាបូបស្ពាយចំហៀងពណ៌សលាយខ្មៅរបស់ជនរងគ្រោះបានសម្រេចរួចជិះម៉ូតូគេចខ្លួន ។ ជនសង្ស័យបានយកប្រាក់ក្នុងកាបូបចំនួន៣០០០ដុល្លារអាមេរិក ចំណែកកាបូបជនរងគ្រោះជនសង្ស័យបោះចោលកន្លែងចាក់សម្រាម ។

-បានឃើញ របាយការណ៍សំយោគលេខ ០៩ របក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៥៣៨ អយប ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣៨៩១ អយប ចុះថ្ងៃ០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥២៨៨ "គ១"ដជ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ ។

## **នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] កុសល បានឆ្លើយថា៖ ខ្ញុំទទួលយកការចោទប្រកាន់គឺនៅថ្ងៃកើតហេតុខ្ញុំពិតជាបានជិះម៉ូតូតែម្នាក់ឯងធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះដែលគៀបនឹងក្លៀកដែលកំពុងតែឈរបានសម្រេចប្រាកដមែនរួចក៏ជិះគេចខ្លួនបាត់ ។ ខ្ញុំបានយកលុយក្នុងកាបូបនោះចំនួ៣០០០ដុល្លារអាមេរិក ចំណែកកាបូបខ្ញុំបោះចោលនៅកន្លែងសម្រាម ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានឃើញថាជនជាប់ចោទបានឆ្លើយសារភាព ដូចនេះសុំតម្កល់បទចោទដូចក្នុងដីកាសន្និដ្ឋានស្ថាពរ និងសុំឲ្យចៅក្រមពិចារណាតាមច្បាប់ ។

-មេធាវី [redacted] ធ្វើសេចក្តីសន្និដ្ឋានថាកូនក្តីខ្ញុំបានសារភាពនិងសន្យាកែប្រែខ្លួន ហើយទើបតែប្រព្រឹត្តលើកទី១ ដូចនេះសុំឱ្យផ្តល់ស្ថានសម្រាលដល់កូនក្តីខ្ញុំ ។

-ជនជាប់ចោទឈ្មោះ [redacted] កុសល សំណូមពរឲ្យតុលាការជួយបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

## **យល់ឃើញថា**



Scanned with CamScanner

-កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ពិតជាមានករណី **លួចមានស្ថានទម្ងន់ទោស** មួយបានកើតឡើងនៅចំណុចមុខផ្ទះលេខ៣៣១ ផ្លូវលេខ៣៥៥ ក្រុម១ ភូមិទួលគោក សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] កុសល ហៅ ស្ពាស់ ភេទប្រុស អាយុ២៧ឆ្នាំ បានជិះម៉ូតូតែម្នាក់ឯងធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះបានសម្រេចប្រាកដមែន ។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **កុសល** ឆ្លើយថាខ្លួនពិតជាបានជិះម៉ូតូធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះបានសម្រេចប្រាកដមែន ។ ឃើញថាចម្លើយនេះមានភាពស៊ីសង្វាក់នឹងចម្លើយដែលបានឆ្លើយគ្រប់ដំណាក់កាល ដូចនេះចម្លើយរបស់ជនជាប់ចោទនាពេលសវនាការអាចឱ្យតុលាការជឿជាក់បាន ។

-មានភាពស៊ីសង្វាក់គ្នារវាងចម្លើយរបស់ជនជាប់ចោទ និងតាមការពិនិត្យឯកសារជាភស្តុតាងផ្សេងៗទៀតក្នុងសំណុំរឿងអាចឱ្យតុលាការកំណត់បាននៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ជនជាប់ចោទឈ្មោះ [redacted] **កុសល ហៅ ស្ពាស់** ភេទប្រុស អាយុ២៧ឆ្នាំ ពិតជាបានជិះម៉ូតូធ្វើសកម្មភាពឆក់យកកាបូបរបស់ជនរងគ្រោះបានសម្រេចប្រាកដមែន ។ អំពើនេះច្បាប់បានកំណត់ជាបទល្មើស **លួចមានស្ថានទម្ងន់ទោស** ដោយមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទជានីតិជនដែលមាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថាជននេះមានវិបល្លាសស្មារតីកើតចេញពីអំពើរបស់ខ្លួនដែលស្ថិតក្នុងលក្ខខណ្ឌនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ហេតុនេះត្រូវតែទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន ។

-មានភស្តុតាង ពិរុទ្ធភាព និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] កុសល ហៅ **ស្ពាស់** ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅខេត្តស្វាយរៀង ទីលំនៅមុនពេលឃុំខ្លួនស្នាក់នៅផ្ទះជួល ផ្លូវបេតុង ភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ បាន ធា "រស់" ម្តាយឈ្មោះ ម៉ន ធារ៉ា "ស្លាប់" ប្រពន្ធឈ្មោះ ពេជ្រ គ្មានកូន ជានីតិជន ។ ប្រវត្តិនៃការផ្តន្ទាទោសពីមុន ធ្លាប់ជាប់ពន្ធនាគាររយៈពេល២ឆ្នាំពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។ ពីបទ ៖ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ៣៣១ ផ្លូវលេខ៣៥៥ ក្រុម១ ភូមិទួលគោក សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានគឺសុំរក្សាការចោទប្រកាន់លើឈ្មោះ [redacted] កុសល ពីបទ លួចមានស្ថានទម្ងន់ទោស ឃើញថាមានភស្តុតាងគ្រប់គ្រាន់ ដូចនេះគប្បីតុលាការលើកយកមកពិចារណា និងសម្រេចតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] កុសល បានសំណូមពរឱ្យតុលាការជួយបន្ធូរបន្ថយទោស ដូចនេះតុលាការនឹងពិចារណាតាមច្បាប់ ។

## <u>ហេតុដូច្នេះសម្រេច</u>

១.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] កុសល ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤(បួន)ឆ្នាំ ពីបទ ៖ **លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប)** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ៣៣១ ផ្លូវលេខ៣៥៥ ក្រុម១ ភូមិទួលគោក សង្កាត់ទួលសង្កែទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ។ បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|

ហត្ថលេខា និងត្រា៖ [redacted]

---

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

*"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"*

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner